ប្រជុំកោះរ៉ុង A1

ខេត្ត : ក្រុងព្រះសីហនុ

ស្រុក : មិត្តភាព

ផ្ទៃដី (ហិកតា) : ១០.៥៦១

រយៈកំពស់ (ម៉ែត្រ) : ០ ដល់ ៣១៧

កូអរដោនេចំណុចកណ្តាល : ១០° ៤៣′ ជ ១០៣° ១៥′ ក

ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ រួមមានប្រជុំកោះរ៉ុងដែលស្ថិតនៅក្នុងឆកកំពង់សោមប្រហែល២០គីឡូម៉ែត្រនៅភាគខាងលិចនៃក្រុងព្រះសីហនុ ។ កោះដែលធំជាងគេនៅទីនោះគឺកោះរ៉ុង និង កោះរ៉ុងសន្លឹម រីឯកោះតូចៗ រួមមានកោះតា និង កោះពស់ ។ កោះទាំងនោះមានលក្ខណៈជាឆ្នេរខ្សាច់ ថ្ម ផ្ទាំងផ្កាថ្ម (ដែលជានិច្ចកាលមានការថយចុះ) និង តំបន់ព្រៃកោងកាងតូចៗ ព្រមទាំងស្មៅសមុទ្រ ។ រុក្ខជាតិដុះនៅលើកោះ គឺជាប្រភេទព្រៃស្រោង បច្ចុប្បន្នមានការថយចុះដោយសារការកាប់បំផ្លាញនៅតាមកន្លែងជាច្រើន ។ ឆ្នេរខ្សាច់ដែលនៅជាប់នឹងកោះគឺជាកន្លែងពងកូនយ៉ាងសំខាន់សំរាប់ប្រភេទសត្វក្បាលធំខ្សាច់ ។

ប្រភេទសត្វស្លាបសំខាន់ៗ

ឈ្មោះខ្មែរ	ឈ្មោះអង់គ្លេស	ឈ្មោះវិទ្យាសាស្ត្រ	លក្ខណៈវិនិច្ឆ័យIBA
សត្វក្បាលធំខ្សាច់	Malaysian Plover	*Charadrius peronii*	A1

ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក

អណ្តើលិច្ចបៃតង ។

ការគំរាមកំហែងលើជីវៈចំរុះ

កោះទាំងអស់លើកលែងកោះរ៉ុងមួយចេញមិនមានមនុស្សរស់នៅទេ តែមានបន្ទាយទាហានតូចមួយនៅលើកោះរ៉ុងសន្លឹម ការគំរាមកំហែងនៅក្នុងតំបន់នេះ រួមមានការរំខានដោយសារសកម្មភាពមនុស្ស ជាពិសេសសកម្មភាពនេសាទ និង ការប្រមូលយកពងកូនប្រព្រឹត្តដោយអ្នកភូមិ ។ ការអភិវឌ្ឍន៍ផ្នែកទេសចរណ៍ ជាពិសេសនៅលើកោះពស់គឺជាការគំរាមកំហែងដែលមានសក្តានុពលនាពេលអនាគត ដែលវាអាចរំខានដល់ឆ្នេរខ្សាច់ដែលជាកន្លែងពងកូនរបស់សត្វក្បាលធំខ្សាច់ ។

អនុសាសន៍

ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្នែកទេសចរណ៍ណាមួយនៅក្នុងតំបន់នេះមិនគួរធ្វើឡើងទេ បើគ្មានការវាយតំលៃហេតុប៉ះពាល់បរិស្ថានឱ្យបានត្រឹមត្រូវ និង ការយល់ដឹងឱ្យបានស៊ីជំរៅនៃតទ្ធិផលជាអវិជ្ជមានលើប្រព័ន្ធអេកូឡូស៊ីឆ្នេរសមុទ្រ ។

ឯកសារយោង

Goes, F. ed. (1999) Recent sightings. *Cambodia Bird News* 1: 20-23.
Goes, F. ed. (1999) Recent sightings. *Cambodia Bird News* 3: 39-43.
Goes, F. ed. (2000) Recent sightings *Cambodia Bird News* 4: 34-38
Goes, F. and Davidson, P. eds. (2001) Recent sightings. *Cambodia Bird News* 8: 44-51.
Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.